**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុរាមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

**អត្ថបទសារព័ត៌មាន**

# អេ អាយ អេ ខេមបូឌា អបអរខួប ៨ឆ្នាំនៃវឌ្ឍនភាព

**ភ្នំពេញ ថ្ងៃទី ០២ ឧសភា ២០២៥៖** ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាព អេ អាយ អេ ខេមបូឌា បានប្រារព្ធខួប ៨ឆ្នាំជាមួយមោទនភាព ដែលបង្ហាញពីដំណើរនៃការប្តេជ្ញាចិត្តឥតងាករេក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជា និងសុខភាពសហគមន៍។

ក្នុងរយៈពេល ៨ឆ្នាំកន្លងមកនេះក្រុមហ៊ុនបានបោះជំហានទៅមុខយ៉ាងរហ័ស បានក្លាយជាដៃគូផ្តល់សន្តិភាពផ្លូវចិត្ត និងទំនុកចិត្តដល់បុគ្គល និងគ្រួសាររាប់សែនគ្រួសារ តាមរយៈបំពេញតម្រូវការលើការការពារ និងផ្នែកហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យអតិថិជនរបស់ខ្លួនអាចផ្តោតលើអ្វីដែលសំខាន់បំផុតដើម្បីសម្រេចគោលដៅជីវិតរបស់ខ្លួន។

ចាប់តាំងពីបើកដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០១៧ អេ អាយ អេ ខេមបូឌា មានបេសសកម្ម និងគោលបំណងជាក់លាក់មួយ នោះគឺជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។ ដំណើរតាមគន្លងនៃបេសកកម្មជាមួយការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងរយៈពេល ៨ឆ្នាំកន្លងមកនេះ ធ្វើឱ្យ អេ អាយ អាយ ខេមបូឌា ក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពឈានមុខគេនៅកម្ពុជា តាមរយៈដំណោះស្រាយធានារ៉ាប់រងប្រកបដោយភាពច្នៃប្រឌិត និងសេវាកម្មល្អឥតខ្ចោះ ដើម្បីបំពេញតម្រូវការអតិថិជនគ្រប់មជ្ឈដ្ឋាន។

ទិន្នន័យនៃលទ្ធផលលើដំណោះស្រាយហិរញ្ញវត្ថុរបស់ អេ អាយ អេ ខេមបូឌា ត្រូវបានបង្ហាញតាមរយៈបទពិសោធរបស់អតិថិជនក្នុងការជួយឱ្យពួកគាត់ទទួលបានសន្តិភាពផ្លូវចិត្ត និងលំនឹងហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំទី 8 នេះ អេ អាយ អេ ខេមបូឌា បានផ្តល់ ការការពារលើដំណោះស្រាយហិរញ្ញវត្ថុដល់គ្រួសារជាង ១៣០,០០០*សារ ដោះស្រាយករណីទាមទារសំណងចំនួន ២៧,០០០* ករណី និងបានផ្តល់អត្ថប្រយោជន៍និងសំណងជូនអតិថិជនសរុបជាង ១០,០០០,០០០* ដុល្លារ។

គ្រួសារជាច្រើនទទួលបានភាពកក់ក្តៅ និងមានក្តីសង្ឃឹមឡើងវិញតាមរយៈការជ្រោមជ្រែងពីក្រុមហ៊ុនអំឡុងពេលប្រឈមនឹងកាលៈទេសៈដ៏លំបាកបំផុតក្នុងជីវិត។ សាច់រឿងគ្រប់រសជាតិ និងការតស៊ូដើម្បីយកឈ្នះឧបសគ្គ បានបង្ហាញអំពីការសន្យាចំពោះបេសកកម្មរបស់ អេ អាយ អេ ខេមបូឌា ក្នុងការជួយគាំទ្រយ៉ាងខ្ជាប់ខ្ជួនដើម្បីពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុ សន្តិភាពផ្លូវចិត្ត និងការគាំទ្រដល់សហគមន៍។

អេ អាយ អេ ខេមបូឌា ស្គាល់ច្បាស់អំពីតួនាទីរបស់ខ្លួនក្នុងការរួមចំណែកដល់សុខុមាលភាពជាតិទាំងមូល។ ក្នុងរយៈពេល ៨ឆ្នាំកន្លងមកនេះ ក្រុមហ៊ុនបានបង្កើតគំនិតផ្តួចផ្តើមដែលជាប្រយោជន៍ដល់សហគមន៍ជាច្រើន រួមទាំងកម្មវិធីសុខភាព អប់រំ និងគម្រោងក្រោមរូបភាពជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការក្នុងស្រុក ក្នុងគោលបំណងលើកកម្ពស់ប្រទេសកម្ពុជាឱ្យកាន់តែរឹងមាំ និងមានសុខភាពល្អ។

គំនិតផ្តួចផ្តើមធំៗទាំងនោះរួមមាន យុទ្ធនាការ AIA Fit For Hope ជាយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីជំងឺមហារីកសុដន់ធំបំផុតនៅកម្ពុជា ដែលសរុបមកដល់បច្ចុប្បន្នយុទ្ធនាការនេះបានផ្តល់ការពិនិត្យជំងឺមហារីកសុដន់ដោយឥតគិតថ្លៃដល់ស្ត្រីជាង ២០,០០០*នាក់។ កម្មវិធីបាល់ទាត់វិលជុំកុមារនិងយុវជន AIA-ISF Youth League ជាថ្នាលបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា បានផ្តល់ឱកាសដល់កុមារនិងយុវជនជួបការខ្វះខាតជាង ១០,០០០*នាក់ ឱ្យបានលេងបាល់ទាត់ក្នុងបរិយាកាសរួសរាយ សុវត្ថិភាព ក៏ដូចជាជួយលើកកម្ពស់សុខភាព បណ្តុះស្មារតីជាអ្នកកីឡា និងចេះធ្វើការជាក្រុម ដែលទាំងអស់នេះទុនដើម្បីអនាគតត្រចះត្រចង់របស់ពួកគេ។ គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពហិរញ្ញវត្ថុសម្រាប់ស្ត្រីកម្ពុជា ក្រោមកិច្ច

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្តបទសារព័ត៌មាន

សហការជាមួយក្រសួងកិច្ចការនារី បានផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រី និងគ្រួសារជាង ១៥,០០០*នាក់ នៅក្នុងខេត្តកំពង់ចាម បាត់ដំបង សៀមរាប និងកំពត។

លទ្ធផលវិជ្ជមាននៃភាពជាដៃគូដ៏រឹងមាំរបស់ អេ អាយ អេ ខេមបូឌា ទាំងវិស័យឯកជន វិស័យសាធារណៈ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានរួមចំណែកយ៉ាងសំខាន់ដល់ភាពជោគជ័យរបស់ខ្លួន ដែលអនុញ្ញាតឱ្យក្រុមហ៊ុនបានចុះទៅដល់សហគមន៍នៅទូទាំងប្រទេសកម្ពុជា និងផ្តល់ដំណោះស្រាយធានារ៉ាប់រងអាយុជីវិត និងសុខភាពឈានមុខគេ រួមជាមួយគំនិតផ្តួចផ្តើមទាក់ទងនឹងសុខភាព។

ក្នុងឱកាសខួបលើកទី ៨ នេះ អេ អាយ អេ ខេមបូឌា ក៏បានអបអរសាទរដល់ដំណើរជោគជ័យលើផ្នែកធនធានមនុស្សរបស់ខ្លួនតាមរយៈសមិទ្ធិផលជាប្រវត្តិសាស្រ្តនៅក្នុងវិស័យធានារ៉ាប់រងកម្ពុជា ពោលគឺ អេ អាយ អេ ខេមបូឌា ជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងដែលមានទីប្រឹក្សាផែនការជីវិតសម្រេចបានបទដ្ឋានពិភពលោក Top of The Table (TOT)។ ទន្ទឹមនឹងនេះផងដែរ ក្រុមហ៊ុនក៏បានគ្រងតំណែងលេខមួយដែលមានទីប្រឹក្សាផែនការជីវិតសម្រេចបទដ្ឋាន MDRT ច្រើនជាងគេនៅកម្ពុជាដែលសបញ្ជាក់អំពីភាពជាអ្នកដឹកនាំរបស់ខ្លួនក្នុងវិស័យធានារ៉ាប់រងកម្ពុជា។ ការទទួលស្គាល់ទាំងនេះ ក៏ជាសក្ខីភាពលើគុណភាពការងារ ភាពស្មោះត្រង់ និងការលះបង់របស់ទីប្រឹក្សាផែនការជីវិត ចំពោះសហគមន៍ដែលពួកគាត់បានធ្វើការជាមួយ បន្ថែមពីលើគោលបំណងរបស់ខ្លួនក្នុងការជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។

នាកម្មវិធីថ្ងៃនោះ លោកស្រី Jane Tay អគ្គនាយិកា អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា “ដំណើររបស់យើងខ្ញុំបានចាប់ផ្តើមជាមួយនឹងគោលបំណងសាមញ្ញមួយ នោះគឺបង្កើតភាពវិជ្ជមានដ៏ពិតប្រាកដដើម្បីជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។ ថ្ងៃនេះ យើងខ្ញុំសាទរភាពជោគជ័យ និងលទ្ធផលរបស់ក្រុមហ៊ុនលើភាពខ្លាំងចំណុចពិសេសជាងគេ និងសមត្ថភាពលេចធ្លោ ដោយរាប់ចាប់ពីគ្រឹះហិរញ្ញវត្ថុដ៏រឹងមាំរហូតដល់ភាពឈានមុខគេមួយក្នុងទីផ្សារ និងតំណាងចែកចាយល្អគ្មានផ្ទឹម”។

លោកស្រី Jane Tay បានបន្ថែមទៀតថា "សមិទ្ធិផលទាំងនេះ គឺជាលទ្ធផលនៃភាពជាដៃគូដ៏រឹងមាំលើគ្រប់វិស័យ ទាំងវិស័យឯកជន វិស័យសាធារណៈ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ ការប្រារព្ធខួបនេះ មិនមែនគ្រាន់តែជាការអបអរសាទរចំពោះសមិទ្ធផលរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែជាការប្រកាសបន្តបង្កើតលទ្ធភាពការងារកាន់តែសកម្មសម្រាប់អនាគត។ គោលដៅនៃដំណើររបស់យើង គឺនៅឆ្ងាយជាងនេះ ប៉ុន្តែតាមរយៈទំនុកចិត្តរបស់អតិថិជន អេ អាយ អេ ខេមបូឌា នឹងបន្តខិតខំដើម្បីបង្កើតភាពជោគជ័យរួមគ្នា សម្រាប់អនាគតកាន់តែប្រសើរ"។

ទន្ទឹមនឹង អេ អាយ អេ ខេមបូឌា ប្រារព្ធភាពជោគជ័យនេះ ក្រុមហ៊ុននៅតែផ្តោតលើគោលបំណងរបស់ខ្លួន ជាមួយនឹងផែនការកែលម្អ និងការច្នៃប្រឌិតជាបន្តបន្ទាប់ ដើម្បីបំពេញតម្រូវការរបស់អតិថិជន លើកកម្ពស់គុណភាពជីវិត និងជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរឡើង។

*តួលេខគិតត្រឹម ឬមុនថ្ងៃចេញអត្ថបទកាសែត*

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

**អំពី អេ អាយ អេ ខេមបូឌា**

*ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*
*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជា ផ្តល់ដំណោះស្រាយការពារលើជំងឺធ្ងន់ធ្ងររហូតដល់ 118 ករណីដំបូងគេនៅកម្ពុជាចាប់ពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយ។*
*ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា  អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*
*អេ អាយ អេ ខេមបូឌា ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ AIA Fit for Hope របស់យើងជាដើម។*
*យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លិបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លិបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*
*អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 5ឆ្នាំជាប់គ្នាពី 2020 ដល់ 20234 អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*

---

ទំនាក់ទំនងសារព័ត៌មាន

រ៉េន ពិសាល
ប្រធានផ្នែកទំនាក់ទំនងសាជីវកម្ម
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
pisal-p.ren@aia.com